

# ព័ត៌មានខ្លេយតុន

ខែវិច្ឆិកា ឆ្នាំ ២០១០
អាសយដ្ឋាន 270 Clayton Road, Clayton
PO Box 5019, Clayton, Victoria 3168
ទូរស័ព្ទ: 03 9558 6058 គេហទំព័រ: www.honglimmp.com

## ការស្វាគមន៍ពីលោក ហុង លីម

ខ្ញុំបាទឈ្មោះ ហុង លីម ជាសមាជិកសភាតំបន់ខ្លេយតុន និងជាទីប្រឹក្សាពិសេសជូនរដ្ឋមន្ត្រីទី១អំពីទំនាក់ទំនងពាណិជ្ជកម្មវិចតូរីយ៉ា-អាស៊ី ។ ខ្ញុំបាទបានជាប់ឆ្នោតជាសមាជិកសភារដ្ឋវិចតូរីយ៉ាចាប់តាំងពីឆ្នាំ១៩៩៦មកម្ល៉េះ ហើយបាននិងកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបន្តធ្វើអោយតំបន់ខ្លេយតុន និងរដ្ឋវិចតូរ៉យ៉ាទាំងមូលប្រែក្លាយទៅជាតំបន់កាន់តែស្រួលរស់នៅ កាន់តែស្រួលធ្វើការសម្រាប់លោកអ្នកនិងគ្រួសារ ព្រមទាំងសហគមន៍របស់លោកអ្នក។



លោក John Brumby
រដ្ឋមន្ត្រីទី១

លោកតំណាងរាស្ត្រ
ហុង លីម

ខ្ញុំបាទសូមស្វាគមន៍ និងសូមអញ្ជើញបងប្អូនអានព្រឹត្តិប័ត្រព័ត៌មានខ្លេយតុននេះដោយរីករាយនិងចូលទៅគេហទំព័ររបស់ខ្ញុំ www.honglimmp.com ដើម្បីអានព័ត៌មានថ្មីៗបំផុតដែលទាក់ទងនឹងរូបខ្ញុំ ក៏ដូចជាទាក់ទងនឹងតំបន់ខ្លេយតុន និងរដ្ឋាភិបាលវិចតូរ៉យ៉ាផងដែរ។

## សហគមន៍នៅ Springvale ទទួលបាន មូលនិធិលើកតំកើងវប្បធម៌



វប្បធម៌ដ៏រឹងមាំនៅតំបន់ Springvale ដែលផ្សារភ្ជាប់នឹងសហគមន៍ជនជាតិចិន វៀតណាម និងខ្មែរនឹងត្រូវបានពង្រឹងបន្ថែមទៀតតាមរយៈការសាងសង់ក្លោងទ្វារថ្មីមួយ ព្រមជាមួយនឹងការពង្រីកទីធ្លាសហគមន៍។

លោក James Merlino រដ្ឋមន្ត្រីជំនួយការរដ្ឋមន្ត្រីទី១លើកិច្ចការពហុវប្បធម៌បានមានប្រសាសន៍ថា សមាគមធុរកិច្ចអាស៊ីស្រ្ពីងវែល (Springvale Asian Business Association) និងសមាគមនខ្មែរវិចតូរីយ៉ា ទទួលបានមូលនិធិចំនួន **២៥០,០០០ដុល្លារ** ពីរដ្ឋាភិបាលគណបក្សពលកររបស់លោក John Brumby សម្រាប់តំបន់ Springvale ។

លោករដ្ឋមន្ត្រីមានប្រសាសន៍ថា រដ្ឋវិចតូរីយ៉ាមានមោទនភាពជាមួយនឹងមតិកវប្បធម៌របស់យើង ។ យើងទាំងអស់

▶តទៅទំព័រ៣

# ១ លានដុល្លារសម្រាប់លើកកម្ពស់ ផ្នែកសារព័ត៌មានជនជាតិភាគតិចក្នុងរដ្ឋវិចតូរីយ៉ា



លោករដ្ឋមន្ត្រីទីមួយ John Brumby បានប្រកាសកាលពីថ្ងៃទី ២៨ ខែតុលាថា  បើគណបក្សពលករជាប់ឆ្នោតម្តងទៀតនោះ ជំនួយថវិកាចំនួន **១លានដុល្លារ** នឹងត្រូវបានផ្តល់ទៅអោយ ផ្នែកសារព័ត៌មានពហុវប្បធម៌ និងជនជាតិភាគតិចរបស់រដ្ឋវិចតូរីយ៉ា ដើម្បីបន្តគាំទ្រសកម្មភាពសម្រាប់សហាគមន៍ចំរុះតទៅទៀត។

លោក John Brumby មានប្រសាសន៍ថា បើជាប់ឆ្នោតម្តងទៀត រដ្ឋាភិបាលគណបក្សពលករ នឹងវិនិយោគលើកម្មវិធីជំនួយថវិការដ្ឋថ្មីមួយ ដែលជួយដល់អង្គភាពសារព័ត៌មានពហុវប្បធម៌ និងជនជាតិភាគតិចក្នុងរដ្ឋវិចតូរីយ៉ា ជាសម្ភារៈបរិក្ខារផ្សេងៗដែលដើរទាន់ទៅនឹងបច្ចេកវិទ្យាទំនើប ដើម្បីបម្រើដល់ភាពចាំបាច់របស់ពួកគេ។

ជារៀងរាល់សប្តាហ៍ អ្នកធ្វើការងារស្ម័គ្រចិត្តជាង ៧០០នាក់ បានបង្កើតកម្មវិធីជាង៦០០ម៉ោង ជាភាសាជាង ១០០ភាសា ដោយមានការចូលរួមពីស្ថានីយ៍វិទ្យុសហាគមន៍ចំនួន ២៨ទូទាំងទីប្រជុំជន ទីជនបទ និងតំបន់ដាច់ស្រយាលក្នុងរដ្ឋវិចតូរីយ៉ា ហើយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងរដ្ឋវិចតូរីយ៉ាជាង ៧សែននាក់ ។

ក្នុងរយៈពេល ១៥ឆ្នាំកន្លងមកនេះ ឃើញថា ចំនួនស្ថានីយ៍ដែលទទួលបានអាជ្ញាប័ណ្ណស្របច្បាប់រយៈពេលវែងក្នុងរដ្ឋវិចតូរីយ៉ា បានបង្កើនការងារផ្សព្វផ្សាយរបស់ ខ្លួនទៅដល់ទូទាំងរដ្ឋវិចតូរីយ៉ា បានប្រមាណជា ៥០ភាគរយ ។

លោក Brumby មានប្រសាសន៍ថា ប្រជាជនក្នុងរដ្ឋវិចតូរីយ៉ាជាង ៤០ភាគរយ មានដើមកំណើតនៅក្រៅប្រទេស ឬមានឪពុកម្តាយមកពីបរទេស ដែលនេះជាកត្តាដែលធ្វើអោយរដ្ឋវិចតូរីយ៉ាក្លាយជាកន្លែងប្រមូលផ្តុំចំរុះពហុវប្បធម៌ច្រើនជាងគេមួយក្នុងពិភពលោក ហើយយើងបាននិងកំពុងខិតខំប្រឹងប្រែងដើម្បីកសាងនូវសហាគមន៍ពហុវប្បធម៌មួយដែលទាមទារអោយយើងទាំងអស់គ្នាធ្វើការរួមគ្នានិងធ្វើយ៉ាងណាដើម្បីធ្វើអោយរដ្ឋវិចតូរីយ៉ាយើងក្លាយជាតំបន់ដ៏ល្អបំផុតសម្រាប់ការរស់នៅ ការធ្វើការ និងចិញ្ចឹមគ្រួសារ។

លោកបានបន្ថែមទៀតថា យើងដឹងថាការផ្សាយគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សហាគមន៍ពហុវប្បធម៌   ហើយការវិនិយោគនេះគឺដើម្បីធានាថាអង្គភាពសារព័ត៌មានពហុវប្បធម៌នឹងបន្តចែកចាយនូវសេវាកម្មដែលមានគុណភាពខ្ពស់ទៅដល់សហាគមន៍ចំរុះរបស់យើងទាំងអស់គ្នា៕



# មន្ទីរពេទ្យកុមារម៉ូណាស្ទ



រដ្ឋាភិបាលគណបក្សពលកររបស់លោកJohn Brumby កំពុងសាងសង់ **មជ្ឈមណ្ឌលកុមារម៉ូណាស្ទ** ( **Monash Children’s Centre** )ថ្មីមួយនៅតំបន់ខ្លេយតុនដែលនឹងប្រើប្រាស់ទឹកប្រាក់ចំនួន**២៥០លានដុល្លារ** ។ មជ្ឈមណ្ឌលនេះនឹងផ្តល់សេវាសុខភាពនិងពេទ្យជំនាញថែទាំដល់កុមាររាប់ពាន់រាប់ម៉ឺននាក់ក្នុងមួយឆ្នាំៗ។មជ្ឈមណ្ឌលនេះមានបំពាក់នូវ៖

- គ្រែចំនួន**២៣០**សម្រាប់សេវាកម្មផ្នែកទារក
- បន្ទប់វះកាត់ចំនួន**៣** និងសេវាកម្មថតឆ្លុះដោយកាំរស្មី
- បរិក្ខារសម្រាប់អ្នកជំងឺដែលមិនសម្រាកក្នុងមន្ទីរពេទ្យ
- បរិក្ខារសម្រាប់សង្គ្រោះនិងថែទាំអ្នកជំងឺធ្ងន់ធ្ងរ
- ផ្នែកជំនាញតាមដានការអភិវឌ្ឍប្រព័ន្ធប្រសាទ

មជ្ឈមណ្ឌលកុមារម៉ូណាស្ទនឹងក្លាយជាគំរោងអភិវឌ្ឍន៍មន្ទីរពេទ្យមួយដ៏ធំបំផុតក្នុងចំណោមមន្ទីរពេទ្យធំៗនៅតំបន់ជាយក្រុងក្នុងប្រវត្តិសាស្រ្តរបស់រដ្ឋវិចតូរីយ៉ា។ គ្រាន់តែក្នុងកំឡុងពេលសាងសង់ប៉ុណ្ណោះ មជ្ឈមណ្ឌលនេះជួយបង្កើតការងារបានចំនួន**៨៣៥**រួចស្រេចទៅហើយ៕

# សហគមន៍នៅ Springvale ទទួលបាន មូលនិធិលើកតំកើងវប្បធម៌




◀ តពីទំព័រ ១

មានដើមកំណើតមកពីប្រទេសជាង២០០ និយាយភាសាជាង២០០ និងគោរពជំនឿសាសនាជាង១១០ផ្សេងៗគ្នា ។ យើងទាំងអស់គ្នាកំពុងធ្វើការជាមួយសហគមន៍ អង្គការនិងក្រុមប្រឹក្សាក្នុងតំបន់របស់យើងដើម្បីថែរក្សាមតិកវប្បធម៌របស់យើងតាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍និងតំបន់វប្បធម៌ដោយការប្រើប្រាស់**មូលនិធិតំបន់វប្បធម៌និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍និងតំបន់វប្បធម៌**ដែលមានទឹកប្រាក់ចំនួន **១០លានដុល្លារ** ។

លោកបានបន្ថែមទៀតថា “មូលនិធិនេះនឹងជួយបង្កើតនូវសារៈប្រយោជន៍ដ៏សំខាន់ សម្រាប់សហគមន៍អាស៊ីនៅតំបន់ Springvale ដែលជាតំបន់បេះដូងសង្គមរបស់សហគមន៍ជនជាតិចិន វៀតណាម និងខ្មែរ។”

លោក Merlino មានប្រសាសន៍បន្តទៀតថា ថវិកាចំនួន**១៧៥,០០០ដុល្លារ** នឹងផ្តល់ទៅឲ្យសមាគមធុរកិច្ចអាស៊ីស្រ្តីងវែលសម្រាប់ការសង់ក្លោងទ្វារអាស៊ីនៅមជ្ឈមណ្ឌលលក់ដូរ Springvale លើចំនុចប្រសព្វរវាងផ្លូវ Buckingham និងផ្លូវ Windsor ។ ហើយទឹកប្រាក់ចំនួន **៨០,០០០ដុល្លារ** បន្ថែមទៀតនឹងផ្តល់ទៅឲ្យសមាគមខ្មែរវិចតូរីយ៉ាសម្រាប់សង់ពង្រីកអគារសមាគម ដែលមានទីតាំងនៅលេខ 52 Queens Street, Springvale ។

លោកតំណាងរាស្រ្ត **ហុង លីម** បានមានប្រសាសន៍ថា មូលនិធិនេះគឺជាមូលនិធិបន្ថែមរបស់មូលនិធិតំបន់វប្បធម៌និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដែលបានអនុវត្តប្រកបដោយជោគជ័យរួចមកហើយនៅតំបន់វប្បធម៌កណ្តាលក្រុងមែលប៊ិនរបស់សហគមន៍ជនជាតិក្រិក អ៊ីតាលី និងចិន។

លោក **ហុង លីម** មានប្រសាសន៍បន្តទៀតថា សហគមន៍អាស៊ីរបស់យើងនឹងបន្តដើរតួនាទីយ៉ាងសកម្មក្នុងការថែរក្សាកិត្តិនាមរបស់យើងក្នុងនាមជាសង្គមចម្រុះដែលពោរពេញទៅដោយមតិកវប្បធម៌ និងសាសនាដ៏សម្បូរបែប ៕

លោក ហុង លីម សមាជិកសភាមណ្ឌលខ្លេយតុន

# ស្ថានីយ៍រថភ្លើង Westall ថ្មី ជាមួយនឹង សេវាកម្មកាន់តែប្រសើរ

អ្នកដំណើរឆ្លងកាត់និងប្រើប្រាស់ស្ថានីយ៍ Westall នឹងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនក្រោយការបើកសម្ពោធឲ្យដំណើរការជាផ្លូវការ ដោយលោករដ្ឋមន្រ្តីដឹកជញ្ជូនសាធារណៈ Martin Pakula កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០កន្លងទៅថ្មីៗនេះ។

ថវិកាចំនួន**១៥៣លានដុល្លារ**ត្រូវបានអនុម័តក្រោមកិច្ចផ្តួចផ្តើមនិងខិតខំប្រឹងប្រែងរបស់លោកតំណាងរាស្រ្ត **ហុង លីម** និងលោករដ្ឋមន្រ្តី Martin Pakula ដើម្បីយកមកប្រើប្រាស់ដូចជា ការសង់បន្ថែមផ្លូវរថភ្លើងមួយខ្សែថ្មីទៀត ការសង់បន្ថែមសំណង់ស្ថានីយ៍ថ្មីមួយទៀត ដែលមានPlatformរង់ចាំថ្មី រួមទាំងទីតាំងចំណតរថយន្តថ្មី ដែលអាចចតយានយន្តបានជាង៨០ និងស្ពានអាកាសសម្រាប់អ្នកថ្មើរជើងឆ្លងកាត់ពីលើផ្លូវដែក ព្រមជាមួយនឹងការបំពាក់នូវប្រព័ន្ធសុវត្ថិភាពនិងបរិក្ខារចាំបាច់មួយចំនួន ហើយមានបុគ្គលិកបម្រើការ និងផ្តល់សេវាកម្មជូន ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ពីព្រឹកព្រលឹមរហូតដល់រថភ្លើងចុងក្រោយគេបង្អស់នាពាក់កណ្តាលយប់អធ្រាតទៀតផង។

ក្នុងថ្ងៃសម្ពោធនិងទស្សនាសមិទ្ធិផលដ៏ត្រចះត្រចង់នេះ លោករដ្ឋមន្រ្តី Martin Pakula បានមានប្រសាសន៍ថា៖

"ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងនិងសូមប្រកាសថាស្ថានីយ៍Westall



លោក **ហុង លីម** និងលោករដ្ឋមន្រ្តីដឹកជញ្ជូនសាធារណៈ Martin Pakula

ថ្មីលំដាប់ខ្ពស់នេះចាប់បើកដំណើរការបម្រើដល់អ្នកដំណើរទាំងអស់ពីពេលនេះតទៅ។"

"លក្ខណៈពិសេសរបស់ស្ថានីយ៍នេះគឺមានបុគ្គលិកប្រចាំការនៅបញ្ជរលក់សំបុត្ររង់ចាំបម្រើសេវាកម្ម ក៏ដូចជាសន្តិសុខពីព្រឹកដល់ពាក់កណ្តាលយប់ មានបន្ទប់រង់ចាំបំពាក់ដោយម៉ាស៊ីនត្រជាក់និងម៉ាស៊ីនកំដៅ មានបន្ទប់ទឹក មានតារាងព័ត៌មានស្តីពីការធ្វើដំណើរ មានបន្ថែមកៅអីអង្គុយរង់ចាំ និងមានបំពាក់ប្រព័ន្ធកាមេរ៉ាសុវត្ថិភាពផងដែរ។"

"ការសាងសង់នៅតែបន្តដំណើរទៅមុខទៀតសម្រាប់គំរោងកែលំអផ្លូវដែកនេះ ដូចជាការសាងសង់ផ្លូវទី៣នៅចន្លោះផ្លូវ Central Road និងSpringvale Road ការពង្រីកបន្ថែមនិងកែលំអទីធ្លាជុំវិញជាដើម ចំណែកការសាងសង់បន្ថែមទីតាំងចំណតរថយន្តនៅប៉ែកខាងជើងស្ថានីយ៍នឹងចាប់ផ្តើមនៅចុងឆ្នាំនេះ។"

លោក **ហុង លីម** បានមានប្រសាសន៍ថ្លែងអំណរគុណចំពោះអ្នកធ្វើដំណើរទាំងអស់ដែលនៅតែបន្តប្រើប្រាស់ស្ថានីយ៍នេះខណៈដែលការសាងសង់គម្រោងដ៏សំខាន់មួយនេះនៅតែបន្ត។

" នៅពេលគម្រោងនេះបញ្ចប់ នោះអ្នកដំណើរទាំងឡាយដែលធ្វើដំណើរតាមផ្លូវដ៏មមាញឹកទៅតំបន់ Dandenong នឹងទទួលបានអត្ថប្រយោជន៍ពីការកែសំរួលប្រព័ន្ធធ្វើដំណើរនេះ។"

" គម្រោងកែលំអផ្លូវដែកWestallនេះនឹងបង្កើនសមត្ថភាពសម្រាប់រថភ្លើងដែលចាប់ផ្តើមចេញដំណើរពីស្ថានីយ៍Westall ហើយនិងជួយកាត់បន្ថយភាពណែនណាន់តាន់តាប់នៅក្នុងរថភ្លើងតាមផ្លូវទៅ Dandenong។"

" រដ្ឋាភិបាលគណបក្សពលកររបស់លោកJohn Brumby បាននិងកំពុងធ្វើការវិនិយោគគួរអោយកត់សម្គាល់ទៅលើគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធយ៉ាងដូចជាគំរោងផ្លូវដែកWestallនេះជាដើមដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃការដឹកជញ្ជូនសាធារណៈ។" ដំណើរការគម្រោងកែលំអផ្លូវដែក Westallនេះរំពឹងថានឹងបញ្ចប់នៅឆ្នាំ២០១១ ខាងមុខនេះ៕

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅក្នុងគេហទំព័រ www.transport.vic.gov.au



